(អត្ថបទបកប្រែក្រៅផ្លូវការ)

# សេចក្តីថ្លែងការណ៍រួម

## ស្តីពីការបង្កើតភាពជាដៃគូយុទ្ធសាស្ត្ររវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

តបតាមការអញ្ជើញរបស់ឯកឧត្តម **យូន ស៊កយ៉ល** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ ពីថ្ងៃទី១៥ ដល់១៨ ខែឧសភា ឆ្នាំ២០២៤។

ក្នុងអំឡុងពេលនៃជំនួបកំពូល ថ្នាក់ដឹកនាំទាំងពីរបានសម្តែងការពេញចិត្តចំពោះការរីកចម្រើនយ៉ាងខ្លាំងនៃទំនាក់ទំនងរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ លើគ្រប់វិស័យ ដែលមានជាអាទិ៍ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ចាប់តាំងពីបានភ្ជាប់ទំនាក់ទំនងការទូតឡើងវិញនៅឆ្នាំ១៩៩៧ ក្រោមការផ្តួចផ្តើមរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាពេលនោះ។

ដោយមានជំនឿទុកចិត្តយ៉ាងមុតមាំចំពោះអនាគតនៃភាពជាដៃគូទ្វេភាគី ភាគីទាំងពីរបានឯកភាពដំឡើងកម្រិតទំនាក់ទំនងរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េទៅជា «ភាពជាដៃគូយុទ្ធសាស្ត្រ» និងបានសម្រេចថានឹងពង្រឹងបន្ថែមទៀតនូវការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើនដូចខាងក្រោម។

### កិច្ចសហប្រតិបត្តិការនយោបាយ សន្តិសុខ និងការពារជាតិ

1. ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះការផ្លាស់ប្តូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងកម្រិតខ្ពស់ជាញឹកញាប់រវាងស្ថាប័ននីតិប្រតិបត្តិ និងនីតិបញ្ញត្តិនៃប្រទេសទាំងពីរ។ ភាគីទាំងពីរបានឯកភាពរក្សា និងបង្កើនសន្ទុះនៃកំណើនការផ្លាស់ប្តូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងគ្នានេះ តាមរយៈការបន្តសម្របសម្រួលទស្សនកិច្ចជាន់ខ្ពស់ក្នុងវិស័យនានា ព្រមទាំងបានបញ្ជាក់អំពីសារសំខាន់នៃការទូតសភាសម្រាប់ការគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក។
2. ភាគីទាំងពីរបានស្វាគមន៍លទ្ធផលប្រកបដោយជោគជ័យនៃកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-កូរ៉េ លើកទី៥ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ និងបានឯកភាពរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះនេះជាទៀងទាត់ ដើម្បីធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសន្ទនាស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី តំបន់និងអន្តរជាតិដែលជាផលប្រយោជន៍រួម។
3. ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការជិតស្និទ្ធលើវិស័យការពារជាតិរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ និងបានបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យការពារជាតិ តាមរយៈសកម្មភាពនានា រួមទាំងការបង្កើតនិងអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានានា ការផ្លាស់ប្តូរទស្សនកិច្ចរបស់មន្ត្រីជាន់ខ្ពស់ ការចូលរួមក្នុងវគ្គអប់រំ និងបណ្តុះបណ្តាល ការជំរុញកិច្ចសហប្រតិបត្តិការប្រឆាំងភេរវកម្ម និងការធ្វើលំហាត់ហ្វឹកហ្វឺន ជាដើម។ ភាគីកម្ពុជាបានស្វាគមន៍គម្រោងចូលចតជាលើកដំបូងរបស់នាវាកងទ័ពជើងទឹកសាធារណរដ្ឋកូរ៉េនៅកម្ពុជា ក្នុងឆ្នាំនេះ។ ភាគីទាំងពីរសង្ឃឹមថានឹងយកឱកាសនៃការចូលចតនេះ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងកងទ័ពជើងទឹកនៃប្រទេសទាំងពីរ។

4. ភាគីទាំងពីរបានកត់សម្គាល់ដោយការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការរឹងមាំក្នុងប្រតិបត្តិការរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ តាមរយៈកម្មវិធីភាពជាដៃគូត្រីភាគីអង្គការសហប្រជាជាតិ-កម្ពុជា-សាធារណរដ្ឋកូរ៉េ។ ភាគីទាំងពីរបានឯកភាពបន្តបង្កើន និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យនេះ ដើម្បីលើកកម្ពស់សន្តិភាព និងសន្តិសុខអន្តរជាតិ។ ភាគីកូរ៉េបានសម្តែងឆន្ទៈក្នុងការបន្តធ្វើការជិតស្និទ្ធជាមួយភាគីកម្ពុជា ដើម្បីពង្រឹងសមត្ថភាពកងកម្លាំងថែរក្សាសន្តិភាពរបស់កម្ពុជា និងផ្តល់ជំនួយដល់កងយោធពលខេមរភូមិន្ទ មានជាអាទិ៍ ការបណ្តុះបណ្តាល ការគាំទ្របច្ចេកទេស និងសម្ភារៈ។

5. ភាគីទាំងពីរបានឯកភាពបង្កើនកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្រេចបាននូវការឆ្លើយតបដែលមានការសម្របសម្រួល និងគ្រប់ជ្រុងជ្រោយចំពោះកំណើនឧក្រិដ្ឋកម្មឆ្លងដែន មានជាអាទិ៍ ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស បទល្មើសបច្ចេកវិទ្យា និងបទល្មើសឆបោក ស្របតាមអនុស្សរណៈនៃការយោគយល់គ្នា និងឯកសារពាក់ព័ន្ធនានារវាងប្រទេសទាំងពីរដែលអាចអនុវត្តបាន។ ភាគីទាំងពីរបានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងសន្តិសុខ និងសុវត្ថិភាពលម្ហសមុទ្រ ដើម្បីលើកកម្ពស់សន្តិភាព និងស្ថិរភាពក្នុងតំបន់។

## កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

6. ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដ៏រឹងមាំរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ជាពិសេសនិន្នាការកើនឡើងនៃវិនិយោគកូរ៉េនៅកម្ពុជា និងការកើនឡើងវិញនៃពាណិជ្ជកម្មទ្វេភាគីនៅក្រោយវិបត្តិជំងឺរាតត្បាតសកលកូវីដ-១៩។ ភាគីទាំងពីរបានឯកភាពទាញយកប្រយោជន៍ជាអតិបរមាពីយន្តការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទ្វេភាគី និងពហុភាគី ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ជាដើម។ ភាគីទាំងពីរបានស្វាគមន៍ការរៀបចំដោយជោគជ័យនូវកិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការចម្រុះនៃ CKFTA ដែលដឹកនាំដោយរដ្ឋមន្ត្រីពាណិជ្ជកម្មកម្ពុជា និងរដ្ឋមន្ត្រីពាណិជ្ជកម្មកូរ៉េ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ នៅសាធារណរដ្ឋកូរ៉េ ព្រមទាំងបានឯកភាពបន្តកិច្ចពិភាក្សាដើម្បីផ្តួចផ្តើមការចរចាលើពាណិជ្ជកម្មសេវាកម្ម និងការវិនិយោគ សំដៅជំរុញបន្ថែមទៀតនូវពាណិជ្ជកម្មទ្វេភាគី និងការវិនិយោគ។ ភាគីទាំងពីរក៏បានឯកភាពបង្កើនកិច្ចសហប្រតិបត្តិការលើពាណិជ្ជកម្មឌីជីថល និងកម្មសិទ្ធិបញ្ញា ដើម្បីការអភិវឌ្ឍប្រកបដោយនវានុវត្តន៍ និងចីរភាព។

7. ដោយកត់សម្គាល់នូវសារសំខាន់នៃសន្តិសុខសេដ្ឋកិច្ច និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃប្រទេសទាំងពីរ ភាគីទាំងពីរបានឯកភាពស្វែងរកមធ្យោបាយធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់។

8. ភាគីទាំងពីរបានឯកភាពរួមគ្នាជំរុញការវិនិយោគរបស់កូរ៉េនៅកម្ពុជា ដោយផ្តោតលើសហគ្រាសធុនតូចនិងមធ្យម និងឧស្សាហកម្មប្រើប្រាស់បច្ចេកវិទ្យាខ្ពស់សម្រាប់បម្រើការនាំចេញ ដូចជា ឧស្សាហកម្មបង្គុំនិងដំឡើងរថយន្ត អេឡិចត្រូនិក បរិក្ខារអគ្គិសនី និងគ្រឿងម៉ាស៊ីន។ ក្នុងកិច្ចប្រឹងប្រែងដើម្បីជំរុញការវិនិយោគទ្វេភាគី ភាគីទាំងពីរបានឯកភាពបង្កើតការពិគ្រោះយោបល់ជាទៀងទាត់រវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា ដើម្បីបង្កើតនូវបរិយាកាសវិនិយោគអំណោយផលសម្រាប់ក្រុមហ៊ុនកូរ៉េ។ ក្នុងន័យនេះ ភាគីទាំងពីរបានឯកភាពជំរុញកិច្ចសហការជិតស្និទ្ធរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយក្រសួង

ពាណិជ្ជកម្ម ឧស្សាហកម្ម និងថាមពលកូរ៉េ ស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា និងទីភ្នាក់ងារជំរុញពាណិជ្ជកម្ម-វិនិយោគកូរ៉េ ក្នុងគោលបំណងស្វែងរកលទ្ធភាពនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា-សាធារណរដ្ឋកូរ៉េ ដើម្បីសម្របសម្រួល និងទាក់ទាញគម្រោងវិនិយោគបន្ថែមទៀតពីកូរ៉េមកកាន់កម្ពុជា។

9. ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការរឹងមាំលើវិស័យហិរញ្ញវត្ថុរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ក្នុងនោះរួមមានការវិនិយោគរបស់កូរ៉េក្នុងស្ថាប័នហិរញ្ញវត្ថុចំនួន១៥ នៅកម្ពុជា និងបានឯកភាពជំរុញកិច្ចសហប្រតិបត្តិការបន្ថែមទៀតក្នុងវិស័យនេះ ដោយផ្តោតលើការប្រើប្រាស់ហិរញ្ញវត្ថុឌីជីថល។

10. ភាគីទាំងពីរបានកត់សម្គាល់នូវវឌ្ឍនភាពនៃទីផ្សារមូលបត្រនៅកម្ពុជា ដែលផ្សារមូលបត្រកម្ពុជាជាការវិនិយោគរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ ភាគីទាំងពីរបានឯកភាពបង្កើនកិច្ចសហប្រតិបត្តិការរវាងនិយ័តករមូលបត្រនៃប្រទេសទាំងពីរ ជាពិសេសលើផ្នែកមូលបត្រឌីជីថល បច្ចេកវិទ្យាហិរញ្ញវត្ថុ និងសញ្ញាប័ណ្ណបីរភាព។

11. ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏រឹងមាំក្នុងវិស័យកសិកម្ម ដោយមានគម្រោងជាច្រើនកំពុងដំណើរការនៅប្រទេសកម្ពុជា។ ភាគីទាំងពីរបានឯកភាពបន្តភាពជាដៃគូកិច្ចសហប្រតិបត្តិការក្នុងវិស័យនេះ ដើម្បីជំរុញពាណិជ្ជកម្មកសិកម្ម ព្រមទាំងលើកកម្ពស់ការផ្ទេរបច្ចេកទេស និងបច្ចេកវិទ្យាកសិកម្ម ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងការជំរុញឧស្សាហកម្មកែច្នៃម្ហូបអាហារ។ ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពនៃការបង្កើតមជ្ឈមណ្ឌលសម្រាប់វិស័យកែច្នៃម្ហូបអាហារ។

12. ភាគីទាំងពីរបានកោតសរសើរចំពោះការអនុវត្តដោយជោគជ័យនៃប្រព័ន្ធអនុញ្ញាតមុខរបរ និងកម្មវិធីពលកររដូវកាល ហើយបានឯកភាពពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការលើវិស័យការងារ។ ភាគីកម្ពុជាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ដែលបានជ្រើសរើសពលករកម្ពុជាទៅបម្រើការនៅសាធារណរដ្ឋកូរ៉េ និងផ្តល់ការគាំទ្រដល់ពួកគេ ព្រមទាំងបានផ្តល់ការគាំទ្របច្ចេកទេសដល់ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលសុវត្ថិភាព និងសុខភាពការងារនៅកម្ពុជា។ ភាគីកម្ពុជាក៏បានបង្ហាញក្តីរំពឹងថានឹងទទួលបានការបន្តគាំទ្រពីភាគីកូរ៉េ រួមទាំងការបង្កើនចំនួនកូតា និងឱកាសការងារសម្រាប់ពលករកម្ពុជា។ ភាគីកូរ៉េបានថ្លែងអំណរគុណចំពោះការរួមចំណែកដ៏មានតម្លៃរបស់ពលករកម្ពុជាដល់សេដ្ឋកិច្ចកូរ៉េ។

13. ភាគីទាំងពីរបានសម្តែងការប្តេជ្ញាចិត្តក្នុងកិច្ចសហប្រតិបត្តិការ និងសហការដើម្បីអភិវឌ្ឍរួមគ្នាលើវិស័យឌីជីថលនៅក្នុងប្រទេសទាំងពីរ ជាពិសេសក្នុងវិស័យបច្ចេកវិទ្យាឈានមុខ និងថ្មីៗ តាមរយៈមធ្យោបាយផ្សេងៗ។ ក្នុងន័យនេះ ភាគីទាំងពីរបានស្វាគមន៍ការបង្កើតមជ្ឈមណ្ឌលជាតិបណ្តុះបណ្តាលធុរកិច្ចថ្មីនៃកម្ពុជាកាលពីខែមីនា ឆ្នាំ២០២៤ ក្រោមការផ្តល់ហិរញ្ញប្បទានរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ដែលនឹងរួមចំណែកដល់ការពន្លឿនបរិវត្តកម្មឌីជីថល និងសេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា។

14. ភាគីទាំងពីរបានគូសបញ្ជាក់អំពីសារសំខាន់នៃការជំរុញការអភិវឌ្ឍមនុស្សជំនាន់ក្រោយ ដែលបំពាក់ដោយជំនាញឧស្សាហកម្ម និងឌីជីថល ដើម្បីជំរុញបរិវត្តកម្ម និងនវានុវត្តន៍ឧស្សាហកម្ម។ ក្នុងបរិការណ៍នេះ ភាគីទាំងពីរបានស្វាគមន៍ការចាប់ផ្តើមកម្មវិធីហិរញ្ញប្បទានឥតសំណងថ្មីរបស់ KOICA ដែលមានគោលបំណងផ្តល់ឱកាសដល់យុវជនទទួលបាននូវជំនាញឧស្សាហកម្ម និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) តាមរយៈការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ប្រកបដោយគុណភាព និងកម្មវិធីអាហារូបករណ៍។

15. ដោយទទួលស្គាល់ថាវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ជាវិស័យដែលមានការរីកចម្រើន និងមានសារសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ភាគីទាំងពីរបានឯកភាពបង្កើនកិច្ចសហប្រតិបត្តិការក្នុងវិស័យនេះ។ ជាពិសេស ភាគីកម្ពុជាបានគូសបញ្ជាក់អំពីសារសំខាន់នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធលើការស្រាវជ្រាវ សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ការផ្តល់អាហារូបករណ៍សម្រាប់ការសិក្សាថ្នាក់ក្រោយឧត្តមលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា កិច្ចសហការលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងការផ្ទេរបច្ចេកវិទ្យា។ ភាគីទាំងពីរបានស្វាគមន៍គម្រោងរបស់ KOICA ដែលកំពុងដំណើរការនៅកម្ពុជា មានឈ្មោះថា «ការកសាងសមត្ថភាព និងការបង្កើតបរិយាកាសក្នុងជំនាញ ICT នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)»។

## កិច្ចសហប្រតិបត្តិការសង្គម វប្បធម៌ និងបរិស្ថាន

16. ភាគីទាំងពីរបានកត់សម្គាល់ដោយពេញចិត្តយ៉ាងខ្លាំងចំពោះការងើបឡើងវិញប្រកបដោយស្ថិរភាពនៃការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជននៃប្រទេសទាំងពីរ នៅក្រោយវិបត្តិជំងឺរាតត្បាតសកល។ ភាគីទាំងពីរបានឯកភាពបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់បន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូទ្វេភាគីក្នុងវិស័យទេសចរណ៍តាមរយៈយន្តការផ្សេងៗ។

17. ភាគីទាំងពីរបានគូសបញ្ជាក់អំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការដ៏រឹងមាំលើវិស័យអប់រំរវាងប្រទេសទាំងពីរដែលបានចាប់ផ្តើមតាំងពីមុនពេលភ្ជាប់ទំនាក់ទំនងការទូតឡើងវិញនៅឆ្នាំ១៩៩៧។ ភាគីកម្ពុជាបានថ្លែងអំណរគុណចំពោះភាគីកូរ៉េ ដែលបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការបន្តគាំទ្រដល់ការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់កម្ពុជា។

18. ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការភ្ជាប់សម្ព័ន្ធមេត្រីភាពរវាងខេត្ត និងក្រុងនៃប្រទេសទាំងពីរ ព្រមទាំងបានលើកទឹកចិត្តឱ្យខេត្ត និងក្រុងដទៃទៀតពិចារណាបង្កើតទំនាក់ទំនងសម្ព័ន្ធមេត្រីភាពក្នុងទម្រង់ស្រដៀងគ្នាដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។

19. ភាគីទាំងពីរបានទទួលស្គាល់អំពីសារសំខាន់នៃការរៀបចំទីក្រុងឆ្លាតវៃ ដែលធានានូវបរិយាកាសទីក្រុងប្រកបដោយបរិស្ថានបៃតង បរិយាប័ន្ន ងាយស្រួលរស់នៅ និងមានចីរភាពជាងមុន។ ក្នុងគោលបំណងបង្កើនគុណភាពជីវិតរបស់ប្រជាពលរដ្ឋ ភាគីទាំងពីរបានឯកភាពចែករំលែកបទពិសោធន៍ ឧត្តមានុវត្តន៍ និងដំណោះស្រាយប្រកបដោយនវានុវត្តន៍នៅក្នុងការកសាងទីក្រុងដែលឆ្លាតវៃ មានចីរភាព និងភាពធន់។

20. ភាគីកម្ពុជាបានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រដល់ភាគីសាធារណរដ្ឋកូរ៉េ ចំពោះការគាំទ្រយ៉ាងសកម្មដល់កិច្ចខិតខំប្រឹងប្រែងអភិរក្ស និងជួសជុលឡើងវិញនូវសម្បត្តិបេតិកភណ្ឌវប្បធម៌នៅកម្ពុជា រួមមានប្រាសាទជមនៃក្រុមប្រាសាទព្រះពិធូ និងព្រះលានជល់ដំរី នៃក្រុងអង្គរធំ។ ភាគីទាំងពីរទន្ទឹងរង់ចាំធ្វើការរួមគ្នាដើម្បីអភិរក្សប្រាសាទអង្គរវត្ត ក្រោមអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យបេតិកភណ្ឌវប្បធម៌ដែលបានចុះហត្ថលេខារវាងអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលបេតិកភណ្ឌវប្បធម៌នៃសាធារណរដ្ឋកូរ៉េ កាលពីខែកុម្ភៈ ឆ្នាំ២០២៤។ ភាគីទាំងពីរបានទទួលស្គាល់អំពីសារសំខាន់នៃការកសាងសមត្ថភាពក្នុងការអភិវឌ្ឍវប្បធម៌ និងបានប្តេជ្ញាចិត្តក្នុងការបន្តកិច្ចសហប្រតិបត្តិការលើគម្រោងអប់រំ និងអភិវឌ្ឍវប្បធម៌ ដូចជា គម្រោងបង្កើតវេទិកាអប់រំសិល្បៈក្នុងប្រទេសកម្ពុជា និងគម្រោងអភិរក្សនិងថតចម្លងបណ្ណសារសារមន្ទីរទួលស្លែងចូលក្នុងប្រព័ន្ធកុំព្យូទ័រ។

21. ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចគាំពារប្រជាជនទៅវិញទៅមកក្នុងប្រទេសរៀងខ្លួន ស្របតាមច្បាប់ជាធរមាននៃប្រទេសទាំងពីរ។ ភាគីទាំងពីរបានលើកទឹកចិត្តឱ្យបញ្ចប់ការចរចាឱ្យបានឆាប់លើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងប្រទេសទាំងពីរ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការទៅវិញទៅមករវាងក្រសួងយុត្តិធម៌នៃប្រទេសទាំងពីរ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

22. ភាគីទាំងពីរបានសម្តែងឆន្ទៈក្នុងការបង្កើនបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងការសឹករិចរិលបរិស្ថាន ដោយគូសបញ្ជាក់អំពីកិច្ចប្រឹងប្រែងរួមគ្នាដែលមានជាអាទិ៍ គម្រោងខ្យល់បរិសុទ្ធប្រកបដោយនិរន្តរភាពសម្រាប់អាស៊ាន។ ដោយទទួលស្គាល់អំពីភាពបន្ទាន់នៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ភាគីទាំងពីរបានឯកភាពពន្លឿនបញ្ចប់ការចរចាលើអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងបរិស្ថានកម្ពុជា និងក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងថាមពលនៃសាធារណរដ្ឋកូរ៉េ ដើម្បីអនុវត្តមាត្រា៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។ ភាគីទាំងពីរក៏បានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការតាមរយៈភាពជាដៃគូតំបន់ និងសកល រួមទាំង គំនិតផ្តួចផ្តើមស្តីពីថាមពលគ្មានបំភាយកាបូនរបស់សាធារណរដ្ឋកូរ៉េ។

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

23. ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះស្ថានភាពបច្ចុប្បន្ននៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងប្រទេសទាំងពីរ។ ភាគីកម្ពុជាបានថ្លែងអំណរគុណដល់ប្រជាជន និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា តាមរយៈការផ្តល់ជំនួយអភិវឌ្ឍន៍ជាបន្តបន្ទាប់ ក្រោមកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា។

24. ភាគីសាធារណរដ្ឋកូរ៉េទទួលស្គាល់កម្ពុជាជាដៃគូយុទ្ធសាស្ត្រដ៏សំខាន់ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការបន្តផ្តល់ការគាំទ្រ តាមរយៈការអនុវត្តយុទ្ធសាស្ត្រភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០២១-២០២៥ របស់សាធារណរដ្ឋកូរ៉េ។ យុទ្ធសាស្ត្រនេះផ្តោតលើវិស័យគន្លឹះចំនួន ៤ រួមមាន ការដឹកជញ្ជូន ការគ្រប់គ្រងទឹកនិងសុខាភិបាល/អនាម័យ ការអប់រំ និងអភិវឌ្ឍន៍ជនបទ ដែលស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអាទិភាពរបស់កម្ពុជា ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន។ ភាគីទាំងពីរបានឯកភាពរៀបចំយុទ្ធសាស្ត្រភាពជាដៃគូសម្រាប់ប្រទេសកម្ពុជាសម្រាប់ដំណាក់កាលបន្ទាប់ ក្នុងពេលវេលាសមស្រប។

25. ភាគីទាំងពីរបានស្វាគមន៍ការបន្តកិច្ចសម្របសម្រួលក្របខ័ណ្ឌពាក់ព័ន្ធនឹងឥណទានសម្បទានពីមូលនិធិកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២២-២០៣០ ដែលមានទំហំទឹកប្រាក់រហូតដល់ចំនួន ៣ ពាន់លានដុល្លារអាមេរិក និងបានឯកភាពបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា។ ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះគម្រោងស្ពានមិត្តភាពកម្ពុជា-កូរ៉េ ដែលជានិមិត្តរូបនៃមិត្តភាពដែលរីកចម្រើនឥតឈប់ឈររវាងប្រទេសទាំងពីរ និងបានឯកភាពពន្លឿនការអនុវត្តគម្រោងនេះផងដែរ។

26. ភាគីទាំងពីរបានកត់សម្គាល់ដោយពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការយ៉ាងសកម្មក្នុងវិស័យថែទាំសុខភាព និងបន្តផ្តល់ការគាំទ្រទៅវិញទៅមក ដើម្បីអនុវត្តគម្រោងនានាដោយជោគជ័យ ដូចមានចែងក្នុងកំណត់ហេតុ

កិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-កូរ៉េ លើកទី៥ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ និងគម្រោងផ្សេងៗទៀតដែលទទួលបានការឯកភាពពីភាគីទាំងសងខាង។

27. ភាគីទាំងពីរបានឯកភាពបន្តបង្កើនកិច្ចសហប្រតិបត្តិការក្នុងការគាំទ្រដល់ការគ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈរបស់កម្ពុជា ក្រោមអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ ដែលបានចុះហត្ថលេខាដោយក្រសួងមុខងារសាធារណៈរបស់កម្ពុជា និងក្រសួងគ្រប់គ្រងបុគ្គលិកនៃសាធារណរដ្ឋកូរ៉េ កាលពីខែតុលា ឆ្នាំ២០២១។ បន្ថែមពីលើនេះ ភាគីទាំងពីរបានឯកភាពបង្កើនកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអាស៊ានបូក៣លើវិស័យមុខងារសាធារណៈ។ ភាគីសាធារណរដ្ឋកូរ៉េបានសម្តែងការគាំទ្រលើគម្រោងកសាងសមត្ថភាពរបស់សាលាភូមិន្ទរដ្ឋបាលកម្ពុជា ឆ្នាំ២០២៥-២០២៩ ដែលទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េបានធ្វើការសិក្សា និងអនុម័តរួចហើយ។

**កិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ**

28. ដោយគូសបញ្ជាក់អំពីសារសំខាន់នៃសន្តិភាព និងសន្តិសុខអន្តរជាតិ ពាណិជ្ជកម្មសេរី នីតិរដ្ឋ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងសេរីភាពនៃការធ្វើនាវាចរណ៍ និងការហោះហើរឆ្លងកាត់ ភាគីទាំងពីរបានឯកភាពបន្ត និងពង្រីកកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិពាក់ព័ន្ធនឹងបញ្ហាតំបន់ និងសកល។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តចំពោះកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ព្រមទាំងអង្គការអន្តរជាតិ និងពហុភាគីផ្សេងទៀត។

29. ភាគីទាំងពីរបានអំពាវនាវឱ្យសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េគោរពតាមសេចក្តីសម្រេចចិត្តពាក់ព័ន្ធទាំងអស់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសង្កត់ធ្ងន់អំពីសារសំខាន់នៃកិច្ចសន្ទនាដោយសន្តិវិធី ដើម្បីសម្រេចបាននូវសន្តិភាព និងស្ថិរភាពយូរអង្វែងនៅឧបទ្វីបកូរ៉េ។ ដើម្បីសម្រេចគោលដៅនេះ ភាគីកម្ពុជាបានស្វាគមន៍គំនិតផ្តួចផ្តើម Audacious Initiative របស់សាធារណរដ្ឋកូរ៉េ ដែលមានបំណងសម្រេចឱ្យបាននូវឧបទ្វីបកូរ៉េដែលគ្មានអាវុធនុយក្លេអ៊ែរ មានសន្តិភាព និងវិបុលភាព ដែលនឹងរួមចំណែកដល់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់។

**30.** ភាគីកម្ពុជាបានសម្តែងការគាំទ្រចំពោះសំណើរបស់សាធារណរដ្ឋកូរ៉េ ក្នុងការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-សាធារណរដ្ឋកូរ៉េ នៅឆ្នាំ២០២៤ ដើម្បីអបអរសាទរខួប ៣៥ឆ្នាំ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សាធារណរដ្ឋកូរ៉េ។ បន្ថែមពីលើនេះ ភាគីកម្ពុជាបានស្វាគមន៍គំនិតផ្តួចផ្តើមសាមគ្គីភាពកូរ៉េ-អាស៊ាន (Korea ASEAN Solidarity Initiative) និងទន្ទឹងរង់ចាំការអនុវត្តខ្សែបន្ទាត់សកម្មភាពស្នូលចំនួន ៨ របស់គំនិតផ្តួចផ្តើមនេះ ដើម្បីផលប្រយោជន៍ទៅវិញទៅមក ដោយប្រកាន់ខ្ជាប់នូវមជ្ឈភាពអាស៊ាន។

31. ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការអាស៊ាន-សាធារណរដ្ឋកូរ៉េ ដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់។ ភាគីសាធារណរដ្ឋកូរ៉េក៏បានបញ្ជាក់ជាថ្មីនូវការគាំទ្រចំពោះទស្សនៈវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) ដែលផ្តល់នូវមាគ៌ានាំផ្លូវសម្រាប់ទំនាក់ទំនងរវាងអាស៊ានជាមួយដៃគូខាងក្រៅ តាមរយៈការអនុវត្តនូវកិច្ចសហប្រតិបត្តិការជាក់ស្តែង និងផ្តល់ផលប្រយោជន៍ទៅវិញទៅមកលើវិស័យអាទិភាពចំនួន៤ ដូចដែលបានកំណត់ក្នុង AOIP តាមរយៈយន្តការដឹកនាំដោយអាស៊ាន។ ភាគីកម្ពុជាក៏បានស្វាគមន៍ការប្តេជ្ញាចិត្តរបស់សាធារណរដ្ឋកូរ៉េចំពោះតំបន់

ឥណ្ឌូ-ប៉ាស៊ីហ្វិកដែលសេរី មានសន្តិភាព និងវិបុលភាព ព្រមទាំងបានកត់សម្គាល់ថា AOIP និងយុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិករបស់កូរ៉េ មានគោលការណ៍ជាមូលដ្ឋានរួមគ្នាក្នុងការលើកកម្ពស់សន្តិភាព និងកិច្ចសហប្រតិបត្តិការ។

32. ភាគីកម្ពុជាបានកោតសរសើរសាធារណរដ្ឋកូរ៉េ ចំពោះការគាំទ្រឥតងាករេដល់កិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន ជាពិសេសតាមរយៈការបង្កើនវិភាគទានប្រចាំឆ្នាំដល់មូលនិធិសហប្រតិបត្តិការអាស៊ាន-សាធារណរដ្ឋកូរ៉េ ពី១៦លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២ ដល់ ៣២លានដុល្លារអាមេរិក នៅឆ្នាំ២០២៧។ ភាគីសាធារណរដ្ឋកូរ៉េបានសម្តែងនូវការប្តេជ្ញាចិត្តក្នុងការរួមចំណែកអនុវត្តនូវអាទិភាពនានាក្រោមគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន និងគាំទ្រដល់ការងាររបស់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន។

33. ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពជាវិជ្ជមាននៃកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ដែលបានពង្រឹងនូវការប្តេជ្ញាចិត្តក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន នៅក្នុងអនុតំបន់មេគង្គ និងបានកោតសរសើរការរៀបចំដោយជោគជ័យនូវវេទិកាធុរកិច្ចមេគង្គ-កូរ៉េ លើកទី១១ ដែលដឹកនាំដោយកម្ពុជា និងសាធារណរដ្ឋកូរ៉េ កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុងសេអ៊ូល។ ភាគីកម្ពុជាបានវាយតម្លៃខ្ពស់ចំពោះសាធារណរដ្ឋកូរ៉េ ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសក្នុងតំបន់មេគង្គ ក្រោមផែនការសកម្មភាពមេគង្គ-កូរ៉េឆ្នាំ២០២១-២០២៥ ព្រមទាំងការប្តេជ្ញាចិត្តរបស់សាធារណរដ្ឋកូរ៉េក្នុងការដំឡើងវិភាគទានប្រចាំឆ្នាំរបស់ខ្លួនទ្វេដងដល់មូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-កូរ៉េ ពី៥លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២ ដល់ ១០លានដុល្លារអាមេរិក នៅឆ្នាំ២០២៧។

អំឡុងទស្សនកិច្ច ភាគីទាំងពីរបានចុះហត្ថលេខាលើឯកសារចំនួន៦ រួមមាន (១) ពិធីសារកែសម្រួលកិច្ចសម្រួលក្របខ័ណ្ឌ ស្តីពីការផ្តល់ឥណទានសម្បទានពីមូលនិធិកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២២-២០២៦ (២) អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគ (៣) អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា (៤) លិខិតថ្លែងបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការបង្ក្រាបគ្រឿងញៀន (៥) អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកម្មវិធីអភិវឌ្ឍន៍ជំនាញ និងទេពកោសល្យវិជ្ជាជីវៈ និង (៦) កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងកែលម្អផ្លូវជនបទ ជំហានទី៤។

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រជូនចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ សម្រាប់ការស្វាគមន៍យ៉ាងកក់ក្តៅ និងការផ្តល់បដិសណ្ឋារកិច្ចជូនសម្តេចធិបតី និងគណៈប្រតិភូកម្ពុជា ព្រមទាំងបានអញ្ជើញ**ឯកឧត្តមប្រធានាធិបតី យូន ស៊ុកយ៉ល** ទៅបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា ក្នុងពេលវេលាសមស្របខាងមុខ។

ទីក្រុងសេអ៊ូល ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤